ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
នាយកដ្ឋានអឺរ៉ុប

សេចក្តីប្រកាសព័ត៌មាន

## លទ្ធផលនៃសម័យប្រជុំលើកទី ១ នៃកិច្ចពិគ្រោះយោបល់ទ្វេភាគី កម្ពុជា-ក្រូអាស៊ី រវាង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការបរទេស និងកិច្ចការអឺរ៉ុបនៃសាធារណរដ្ឋក្រូអាស៊ី

នៅថ្ងៃទី៤-៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ឯកឧត្តម យួន ផុនរតនៈ រដ្ឋលេខាធិការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញទៅបំពេញទស្សនកិច្ចការងារនៅសាធារណរដ្ឋក្រូអាស៊ី។

ក្នុងអំឡុងពេលស្នាក់នៅទីក្រុងសាគ្រែប ឯកឧត្តម យួន ផុនរតនៈ បានធ្វើជាសហប្រធានកិច្ចប្រជុំពិគ្រោះយោបល់ទ្វេភាគីលើកទី១ រវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការបរទេស និងកិច្ចការអឺរ៉ុបនៃសាធារណរដ្ឋក្រូអាស៊ី ជាមួយ ឯកឧត្តម Frano Matušić រដ្ឋលេខាធិការនៃក្រសួងការបរទេស និងកិច្ចការអឺរ៉ុបនៃសាធារណរដ្ឋក្រូអាស៊ី។

សហប្រធានទាំងពីរបានចាប់ផ្តើមកិច្ចសន្ទនាដោយបានសម្តែងការពេញចិត្តយ៉ាងខ្លាំងចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អរវាងប្រទេសទាំងពីរ។ សហប្រធានទាំងពីរ ជឿជាក់ថា កិច្ចពិគ្រោះយោបល់ប្រកបដោយផ្លែផ្កានេះ នឹងត្រួសត្រាយផ្លូវសម្រាប់កិច្ចសហប្រតិបត្តិការក្នុងវិស័យថ្មីៗជាច្រើន រួមមានការទូត ពាណិជ្ជកម្ម ការដោះមីន ទេសចរណ៍ ការផ្លាស់ប្តូរប្រជាជន និងប្រជាជន និងវប្បធម៌។ កិច្ចពិគ្រោះយោបល់នេះក៏ជំរុញឱ្យមានការយល់គ្នាទៅវិញទៅមកកាន់តែស៊ីជម្រៅ តាមរយៈការផ្លាស់ប្តូរទស្សនៈលើបញ្ហាតំបន់ និងសកលដែលជាកង្វល់ និងផលប្រយោជន៍រួម។

ឯកឧត្តម យួន ផុនរតនៈ បានលើកឡើងពីដំណើរនៃការប្រែក្លាយសេដ្ឋកិច្ចសង្គមរបស់កម្ពុជាពីប្រទេសដែលហែកហួរដោយសង្គ្រាម ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប និងកំពុងស្ថិតក្នុងមាគ៌ា ឆ្ពោះទៅទទួលបានឋានៈជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ ដែលសមិទ្ធផលនេះទទួលបានពីការកសាងប្រទេសឡើងវិញក្រោយសម័យខ្មែរក្រហម។ ឯកឧត្តមក៏បានលើកឡើងផងដែរនូវកម្មវិធីគោលនយោបាយអាទិភាពទាំង៦ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជាអាណត្តិថ្មីនេះ។ ឯកឧត្តម Frano Matušić បានទទួលស្គាល់ពីប្រវត្តិសាស្ត្រស្រដៀងគ្នារវាងប្រទេសទាំងពីរ ទាក់ទិននិងការយកឈ្នះលើបញ្ហាប្រឈមក្រោយសង្គ្រាម ហើយបានសង្កត់ធ្ងន់លើសារៈសំខាន់នៃសន្តិភាព និងការអភិវឌ្ឍធនធានមនុស្ស ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការកសាងប្រទេស

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855) 23 216 122
ទូរសារ: (855) 23 216 141, 023 213 341
អ៊ីម៉ែល: [illegible]

មាគ៌ានៃការស្តារឡើងវិញនៃប្រទេសទាំងពីរបានជំរុញឱ្យមានការយល់ពីគ្នាទៅវិញទៅមក អំពីដំណើរផ្លាស់ប្តូររបស់ប្រទេសរៀងៗខ្លួនក្នុងការកសាង និងអភិវឌ្ឍន៍ប្រទេស។

ដោយទទួលស្គាល់ពីសក្តានុពលសម្រាប់ការរីកចម្រើនសេដ្ឋកិច្ច ភាគីទាំងពីរបានពិភាក្សាអំពីវិធីសាស្ត្រក្នុងការពង្រីកវិស័យពាណិជ្ជកម្ម និងការវិនិយោគ តាមរយៈយន្តការនានាដូចជា ការបង្កើតអនុស្សរណៈនៃការយោគយល់គ្នា និងការផ្សារភ្ជាប់ទំនាក់ទំនងរវាងសភាពាណិជ្ជកម្មនៃប្រទេសទាំងពីរ និងការរៀបចំវេទិកាធុរកិច្ច។ **ឯកឧត្តម ឃួន ផុនរតនៈ** បានជម្រាបជូនសមភាគីអំពីវិស័យសំខាន់ៗសម្រាប់កិច្ចសហប្រតិបត្តិការ រួមមាន កសិកម្ម ការកែច្នៃម្ហូបអាហារ ការផលិត និងហេដ្ឋារចនាសម្ព័ន្ធ។ **ឯកឧត្តម** Frano Matušić បានគូសបញ្ជាក់អំពីភាពខ្លាំងខាងបច្ចេកវិទ្យារបស់ក្រូអាស៊ី ជាពិសេសក្នុងការកែច្នៃម្ហូបអាហារ។ ឯកឧត្តមក៏បានគូសបញ្ជាក់បន្ថែមថា ដោយផ្អែកលើការឆ្លងកាត់សង្គ្រាមស្រដៀងគ្នានៃប្រទេសទាំងពីរ វិស័យដោះមីនគឺជាវិស័យអាទិភាពសម្រាប់កិច្ចសហការរវាងប្រទេសទាំងពីរ។ **ឯកឧត្តម** Frano Matušić បានជម្រាបជូនអំពីសមត្ថភាពខ្ពស់របស់ក្រូអាស៊ីក្នុងវិស័យដោះមីន និងបានស្នើអ្នកជំនាញកម្ពុជាពិនិត្យលទ្ធភាពបង្កើតឱ្យមានកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុនដោះមីនរបស់ក្រូអាស៊ី ដែលមានបទពិសោធន៍យ៉ាងទូលំទូលាយក្នុងវិស័យនេះ។

ដើម្បីជំរុញវិស័យទេសចរណ៍ និងការផ្លាស់ប្តូរវប្បធម៌ សហប្រធានទាំងពីរបានពិភាក្សាពីលទ្ធភាពក្នុងការបង្កើតឱ្យមានចំណងមេត្រីភាព (Sister-City) រវាងខេត្តសៀមរាប ដែលជាតំបន់វប្បធម៌សំខាន់របស់កម្ពុជា និងទីក្រុង Dubrovnik ដែលជាទីក្រុងប្រវត្តិសាស្ត្រដ៏ល្បីល្បាញរបស់ប្រទេសក្រូអាស៊ី ដោយខេត្តទាំងពីរសុទ្ធតែជាតំបន់ដែលមានសម្បត្តិបេតិកភណ្ឌអង្គការយូណេស្កូ។ កិច្ចសហប្រតិបត្តិការនេះ ផ្តល់ឱកាសដើម្បីជំរុញទេសចរណ៍វប្បធម៌ និងចែករំលែកការអនុវត្តក្នុងវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព។

ដើម្បីត្រៀមប្រារព្ធខួបលើកទី៣០ នៃការបង្កើតទំនាក់ទំនងការទូតនៅឆ្នាំ ២០២៦ ខាងមុខ ភាគីទាំងពីរបានពិភាក្សាអំពីការប្រារព្ធពិធីដ៏សំខាន់នេះ តាមរយៈកិច្ចសន្ទនាកម្រិតខ្ពស់ តាមពេលវេលា និងឱកាសសមស្រប និងការផ្លាស់ប្តូរលិខិតអបអរសាទរកម្រិតថ្នាក់ដឹកនាំជាន់ខ្ពស់។ ខួបទំនាក់ទំនងការទូតនេះគឺជាឱកាសពិសេសមួយដើម្បីបង្ហាញពីទំនាក់ទំនងជាមិត្តភាពរវាងកម្ពុជា-ក្រូអាស៊ី និងស្វែងរកឱកាសកិច្ចសហប្រតិបត្តិការបន្ថែមទៀត។

សហប្រធានបានបិទបញ្ចប់កិច្ចពិគ្រោះយោបល់ ដោយសម្តែងការពេញចិត្តយ៉ាងខ្លាំងចំពោះលទ្ធផលប្រកបដោយផ្លែផ្កា។ បន្ទាប់ពីបញ្ចប់ **ឯកឧត្តម** Frano Matušić បានរៀបចំអាហារថ្ងៃត្រង់ការងារជូនគណៈប្រតិភូកម្ពុជា ដែលនាឱកាសនោះ ភាគីទាំងពីរបានផ្លាស់ប្តូរទស្សនៈគ្នាលើកិច្ចការតំបន់ អន្តរជាតិ និងកិច្ចសហប្រតិបត្តិការពហុភាគី ដែលជាផលប្រយោជន៍រួម។

ក្រៅពីធ្វើជាសហប្រធានដឹកនាំកិច្ចពិគ្រោះយោបល់លើកដំបូងបានជោគជ័យ និងប្រកបដោយសមិទ្ធផល **ឯកឧត្តម ឃួន ផុនរតនៈ** បានដឹកនាំគណៈប្រតិភូកម្ពុជា ដោយមានការសម្របសម្រួលពីក្រសួងការបរទេស និងកិច្ចការអឺរ៉ុបរបស់ក្រូអាស៊ី និងអាជ្ញាធរកំពង់ផែ Rijeka ទៅទស្សនាកំពង់ផែ Rijeka។ ក្នុងកិច្ចពិភាក្សាជាមួយនាយកប្រតិបត្តិ លោក Denis Vukorepa ភាគីទាំងពីរបានជជែកគ្នាពីការស្វែងរកឱកាសសម្រាប់កិច្ចសហប្រតិបត្តិការដែនសមុទ្រតាមរយៈយន្តការ ដូចជា ការចែករំលែកចំណេះដឹង ការផ្សារភ្ជាប់ក្រុមការងារបច្ចេកទេសរួម និងការវិនិយោគកំពង់ផែ។ គណៈប្រតិភូកម្ពុជាក៏បានស្តាប់បទបង្ហាញគួរឱ្យចាប់អារម្មណ៍ពាក់ព័ន្ធនឹងគម្រោងសំខាន់ៗមួយចំនួនរបស់កំពង់ផែ និងបានធ្វើដំណើរទស្សនាគម្រោងសំខាន់ៗដែលកំពុងដំណើរការនៅកំពង់ផែផ្ទាល់ផងដែរ។

ថ្ងៃពុធ ១៣ កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៤